# ការរកមើលគ្រោះថ្នាក់បណ្ដាលពីសារធាតុសំណ

សន្លឹកព័ត៌មានគន្លឹះអំពីសារធាតុសំណ #6

ខែមករា ឆ្នាំ 2023



ផ្ទះដែលបានកសាង មុនឆ្នាំ 1950 ភាគច្រើនទំនងជាលាបថ្នាំមានសារធាតុសំណ ។ ផ្ទះដែលបានកសាងក្នុងរវាងឆ្នាំ 1950 និងឆ្នាំ 1978 អាចប្រើថ្នាំលាបមានសារធាតុសំណ ។ ការពិនិត្យរកមើលសារធាតុសំណក្នុងផ្ទះរបស់អ្នក ឬនៅក្នុងបន្ទប់ផ្ទះជួលរបស់អ្នក អាចជួយអ្នកបានក្នុងការកំណត់សញ្ញាណហានិភ័យបណ្ដាលពីសារធាតុសំណដែលមានសក្ដានុភាព ។ នៅពេលដែលអ្នកដឹងថាត្រូវរកមើលអ្វី គឺវាអាចជួយអ្នក ក្នុងកិច្ចការពារគ្រួសារ ឬអ្នកជួលផ្ទះរបស់អ្នក ឲ្យផុតពីការប្រឈមនឹងសារធាតុសំណ ។

## កន្លែងដែលត្រូវរកមើល

ថ្នាំលាបមានសារធាតុសំណ ភាគច្រើននៅតាម ៖

- បង្អួច និងទ្វារ
- របស់ធ្វើពីឈើ និងគែមរបស់ទាំងនោះ
- កម្រាល និងជណ្ដើរ
- បរិវេណខាងក្រៅ រួមទាំងរានហាល
- ជញ្ជាំងក្នុងបន្ទប់ទឹក និងក្នុងបន្ទប់បាយ

ថ្នាំលាបមានសារធាតុសំណ ជាធម្មតាគេ**មិន**ប្រើវាដើម្បីលាបជញ្ជាំងក្នុងបន្ទប់ នៅក្រៅបន្ទប់បាយ និងបន្ទប់ទឹកឡើយ ។ ថ្នាំលាបប្រភេទនេះ ជាធម្មតាក៏គេ**មិន**ប្រើវា សម្រាប់លាបពិដានដែរ ប្រសិនបើពិដាននោះមិនមែនជាពិដានស័ង្កសី ឬឈើទេនោះ ។ ពិដានរានហាលខ្លះ អាចធ្វើពីឈើ ។ ថ្នាំលាបឲ្យភ្លឺ (វ៉ានីស) ជាធម្មតា**មិន**មានលាយសារធាតុសំណច្រើនទេ ។

ផ្ទះដែលលាបថ្នាំមានលាយសារធាតុសំណ មិនមែនមានន័យថា វាសុទ្ធតែបង្ករគ្រោះនោះទេ ។ ជាទូទៅ ថ្នាំលាបមានលាយសារធាតុសំណ ដែលនៅល្អ មិនត្រូវបានសន្មត់ថាមានគ្រោះថ្នាក់ទេ ។ ថ្នាំលាបដែលប្រេះ របក របើក ឬគ្របដណ្ដប់ដោយធូលីកាកសំណល់ អាចបង្ករគ្រោះថ្នាក់ពីសារធាតុសំណ ហើយអ្នកត្រូវតែដោះស្រាយ ។

## ត្រូវរកមើលសារធាតុសំណញឹកញាប់ប៉ុណ្ណា

ស្ថានភាពនៃថ្នាំលាប ប្រែប្រួលទៅតាមពេលវេលា ។ ត្រូវពិនិត្យរកមើលគ្រោះថ្នាក់បណ្ដាលពីសារធាតុសំណរៀងរាល់ 6 ខែម្ដង និងនៅពេលមានអ្នកជួលថ្មីចូលនៅ បើអ្នក ជាម្ចាស់ផ្ទះជួល ។

## ត្រូវពិនិត្យមើលអ្វីខ្លះ

ដើរមើលជុំវិញផ្ទះ ទាំងខាងក្នុង និងខាងក្រៅ ។ សួរសំណួរទាំងអស់នេះ ៖

1. តើផ្ទះនេះ មានកន្លែងណាដែលថ្នាំលាបប្រេះ របក របើក ឬប្រឡាក់ដៃដូចដីសដែរឬទេ? បើអ្នកយកដៃជូតលើផ្ទៃ តើមានម្សៅធូលី និង/ឬកំទេចថ្នាំជាប់នឹងដៃរបស់អ្នកដែរឬទេ?

2. តើមានលាបថ្នាំត្រង់បរិវេណ ដែលផ្ទៃរបស់វាកោស ឬប៉ះគ្នាដែរឬទេ? ឧទាហរណ៍ ដូចជា បង្អួច ទ្វារ កម្រាល និងជណ្ដើរ ។

3. តើមានផ្ទៃលាបថ្នាំ ដែលក្មេងអាចយកមាត់ទៅប៉ះដែរឬទេ? ឧទាហរណ៍ ដូចជា ៖
   - បន្ទះទម្របង្អួច បង្កាន់ដៃជណ្ដើរ ក្របជើងជញ្ជាំង និងបិរវេណផ្សេងទៀត ដែលធូលីងាយកក
   - ផ្ទៃដែលលៀនចេញកម្រាស់កន្លះអ៊ិញ ឬក្រាស់ជាងនេះ ឬដែលក្មេងអាចប៉ះបាន (4 ហ្វីត ឬទាបជាងនេះ)

4. តើក្នុងបរិវេណផ្ទះមានត្រង់ណាដែលមានតែដីទទេដែរឬទេ? ធូលី និងកំទេចថ្នាំអាចជ្រុះចេញពីថ្នាំលាបដែលមានលាយសារធាតុសំណ នៅផ្នែកខាងក្រៅផ្ទះ និងលើដីនៅក្បែរផ្ទះ ។ សារធាតុសំណអាចស្ថិតនៅក្នុងដីជាច្រើនឆ្នាំ ។

បើចម្លើយ គឺ “បាទ/ចាស” ចំពោះសំណួរណាមួយ គឺវាអាចកើតមានគ្រោះថ្នាក់បណ្ដាលពីសារធាតុសំណ ។ អ្នកអាចស្វែងករកវិធីសម្រាប់ដោះស្រាយគ្រោះថ្នាក់បណ្ដាលពីសារធាតុសំណ តាមអាសយដ្ឋាន www.maine.gov/healthyhomes ។

**ការពារគ្រួសាររបស់អ្នក ។**

- សូមឆែកមើលព័ត៌មានក្នុងវិបសៃត៍នេះ ៖ maine.gov/healthyhomes
- ហៅទូរស័ព្ទទៅលេខនេះ ដើម្បីសុំជំបូន្មាន ៖ **866-292-3474 • អ្នកប្រើ TTY សូមហៅទៅលេខ ៖ លេខបន្តរបស់រដ្ឋមេន 711**